**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៥៧ ព.ណ ស.ល. ប្រក

# ប្រកាស
# ស្តីពី
# ការកែសម្រួលសមាសភាព និងតែងតាំងអ្នកនាំពាក្យក្រសួងពាណិជ្ជកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម ។

## សម្រេច

**ប្រការ ១ ៖** ត្រូវបានកែសម្រួល និងតែងតាំងសមាសភាពអ្នកនាំពាក្យ និងអ្នកសម្របសម្រួលរបស់ក្រសួងពាណិជ្ជកម្ម មានរាយនាម ដូចខាងក្រោម៖

| | | |
|---|---|---|
| **១- ឯកឧត្តម ស៊ាង ថៃ** | **អគ្គនាយកជំរុញពាណិជ្ជកម្ម** | អ្នកនាំពាក្យ |
| **២- លោក ឡុង កែមវិចិត្រ** | **ប្រធាននាយកដ្ឋាន** | អ្នកនាំពាក្យឆ្លាស់វេន |
| **៣- កញ្ញា សឹង សុផារី** | **អនុប្រធាននាយកដ្ឋានអាស៊ី ប៉ាស៊ីហ្វិក** | អ្នកសម្របសម្រួល |

**ប្រការ ២ ៖** អ្នកនាំពាក្យ អ្នកនាំពាក្យឆ្លាស់វេន និងអ្នកសម្របសម្រួល មានភារកិច្ចដូចតទៅ៖

**ភារកិច្ចរបស់អ្នកនាំពាក្យ៖**

- ទាក់ទង និងឆ្លងឆ្លើយ ជាផ្លូវការ ជាមួយសាធារណជន បណ្តាញសារព័ត៌មាន

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA* *Phone/Facsimile: (855)-23 866 469*

- សហការជាមួយអង្គភាពចំណុះរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីប្រមូលព័ត៌មាន និងឯកសារពាក់ព័ន្ធ ក្នុងការស្រាយបំភ្លឺ ជូនសាធារណជន និងបណ្ដាញសារព័ត៌មាន
- សហការជាមួយអង្គភាពចំណុះ និងស្ថាប័នពាក់ព័ន្ធលើបញ្ហាអន្តរវិស័យ សម្រាប់ចងក្រងជាខ្លឹមសារ និងរៀបចំសន្និសីទ សារព័ត៌មាន សម្រាប់កិច្ចប្រជុំ និងព្រឹត្តិការណ៍សំខាន់ៗ របស់ក្រសួងពាណិជ្ជកម្ម
- ស្រាយបំភ្លឺ និងផ្ដល់ព័ត៌មាន ជូនសាធារណជន ឱ្យបានទាន់ពេលវេលា តាមសំណូមពរ និងការចាំបាច់
- បំពេញភារកិច្ចផ្សេងៗ ទៀត តាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

**ភារកិច្ចរបស់អ្នកនាំពាក្យឆ្លាស់វេនៈ**

អ្នកនាំពាក្យឆ្លាស់វេន ត្រូវបំពេញភារកិច្ចជំនួសឲ្យអ្នកនាំពាក្យ ក្នុងករណីអវត្តមាន ឬ មានការប្រគល់ភារកិច្ចដោយអ្នកនាំពាក្យ។

**ភារកិច្ចរបស់អ្នកសម្របសម្រួលៈ**

អ្នកសម្របសម្រួលមានភារកិច្ចជួយបំពេញការងារ និងសម្របសម្រួលការងារជូនអ្នកនាំពាក្យ និងអ្នកនាំពាក្យឆ្លាស់វេន តែពុំមានភារកិច្ចឆ្លើយឆ្លង ឬ ផ្ដល់បទសម្ភាសន៍ជាមួយសាធារណជន ឬ អ្នកសារព័ត៌មានឡើយ។

**ប្រការ ៣ ៖** ប្រកាសទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ ៖** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានគ្រប់អង្គភាព មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងសាមីខ្លួន ត្រូវអនុវត្តតាមសេចក្ដីប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**ចម្លងជូនៈ**

- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យ **សម្ដេចតេជោនាយករដ្ឋមន្ត្រី***
- *ខុទ្ទកាល័យ **សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី***
- *ក្រសួងមុខងារសាធារណៈ*
- *ក្រសួងព័ត៌មាន*
- *ឯកឧត្ដម និងលោកជំទាវ រដ្ឋលេខាធិការ*
- *ឯកឧត្ដម និងលោកជំទាវ អនុរដ្ឋលេខាធិការ "ដើម្បីជូនជ្រាប"*
- *រដ្ឋបាលរាជធានី-ខេត្ត*
- *ដូចប្រការ ៤ "ដើម្បីមុខការ"*
- *ឯកសារ - កាលប្បវត្តិ*